**OFFICE OF THE SUPERINTENDENT**
ការិយាល័យនៃអគ្គនាយកនៃសង្កាត់សាលារៀនអូកឡិនដ៍

**OAKLAND UNIFIED SCHOOL DISTRICT**
*Community Schools, Thriving Students*

4 មីនា 2020

សូមជំរាបសួរប្រជាសហគមន៍ទាំងឡាយនៃសង្កាត់សាលារៀនអូកឡិនដ៍,

សុខភាព និងសុវត្ថិភាពនៃប្រជាសហគមន៍របស់យើង គឺជាអាទិភាពកំពូលរបស់យើង។ នេះគឺជាការផ្តល់ព័ត៌មានថ្មីបំផុតចុងក្រោយ ទាក់ទងនឹងវីរុសកូរ៉ូណា ដែលយើងហៅម្យ៉ាងទៀតថា មេរោគ COVID-19។

ថ្នាក់ដឹកនាំសាលារៀន និងថ្នាក់ដឹកនាំសង្កាត់ បន្តផ្តោតជាសំខាន់លើបញ្ហានេះ ហើយយើងខ្ញុំកំពុងប្រាស្រ័យទាក់ទងជាប្រចាំ ជាមួយនឹងការិយាល័យអប់រំប្រចាំខោណធីអាឡាមីដា (ACOE) និងដៃគូនានារបស់យើង មកពីនាយកដ្ឋានសុខភាពសាធារណៈប្រចាំខោណធីអាឡាមីដា (ACPHD)។

**អ្វីដែលយើងខ្ញុំដឹង**
ព័ត៌មានអំពីមេរោគកូរ៉ូណា គឺមានការប្រែប្រួលជាញឹកញាប់ ប៉ុន្តែអ្វីដែលយើងខ្ញុំដឹងនាពេលនេះ គឺមានជូនដូចខាងក្រោមនេះ៖

- ពុំមានករណីឆ្លងវីរុសកូរ៉ូណានៅតាមទីសាលារៀននានានៃសង្កាត់សាលារៀនអូកឡិនដ៍នោះទេ។
- ដោយសារយើងពុំមានករណីរោគឆ្លងមេរោគកូរ៉ូណានោះ យើងខ្ញុំកំពុងប្រតិបត្តិតាមការណែនាំនានារបស់នាយកដ្ឋានសុខភាពសាធារណៈប្រចាំខោណធីអាឡាមីដាថា យើងពុំចាំបាច់លុបចោលសាលារៀន ឬព្រឹត្តិការណ៍ក្រៅកម្មវិធីសិក្សា (ដូចជា៖ ដំណើរទស្សនកិច្ចសិក្សា, ព្រឹត្តិការណ៍កីឡាជាដើម) នោះទេ។ ប្រសិនបើការណែនាំនេះ ឬស្ថានភាពរបស់យើង មានការប្រែប្រួលនោះ យើងខ្ញុំនឹងផ្តល់ដំណឹងជូនលោកអ្នកឱ្យបានជ្រាបភ្លាមៗ។
- បុគ្គលិកផ្នែកថែទាំរបស់សង្កាត់សាលារៀនអូកឡិនដ៍ កំពុងប្រតិបត្តិតាមបច្ចេកទេសសំអាត និងរម្ងាប់មេរោគឱ្យបានត្រឹមត្រូវជារៀងរាល់ថ្ងៃ។ ដោយមានការប្រុងប្រយ័ត្នច្រើន យើងកំពុងដាក់បញ្ចូលនូវការអនុវត្តន៍ដើរពិនិត្យមើលឱ្យដឹងថាមានសាប៊ូលាងដៃ និងគ្រឿងសំអាតផ្សេងទៀត ហើយយើងខ្ញុំបានដាក់បញ្ជាទិញផលិតផលសំអាត និងអនាម័យក្រៅថែមទៀត ដែលចំណាយអស់ជិតទៅ 250,000 ដុល្លារឯណោះ។
- បុគ្គលិកសង្កាត់ បន្តរៀបចំផែនការនានា ក្រែងលោយើងត្រូវការបិទសាលារៀនក្នុងពេលណាមួយ។ ការសម្រេចចិត្តនេះ នឹងត្រូវបានធ្វើឡើងដោយពិគ្រោះយោបល់ជាមួយនឹងនាយកដ្ឋានសុខភាពសាធារណៈប្រចាំខោណធីអាឡាមីដា និងការិយាល័យអប់រំប្រចាំខោណធីអាឡាមីដា។
- សិស្សសាលា ក្រុមគ្រួសារ និងបុគ្គលិកទាំងអស់នៃសង្កាត់សាលារៀនអូកឡិនដ៍ គប្បីអនុវត្តអនាម័យល្អដើម្បីសុខភាព ដែលក្នុងនោះរួមមានទាំងការលាងដៃ ការស្នាក់នៅផ្ទះ ប្រសិនបើអ្នកមានជម្ងឺឈឺថ្កាត់ ត្រូវចៀសវាងនៅក្បែរមនុស្សដែលមានជម្ងឺឈឺថ្កាត់ ហើយខ្ទប់មាត់របស់អ្នកនៅពេលក្អក ឬកណ្តាស់ ដោយក្រដាស់ជូនមាត់ ឬដៃអាវរបស់អ្នក (មិនមែនដោយដៃផ្ទាល់របស់អ្នកទេ)។
- ការផ្តល់ព័ត៌មានថ្មីបំផុតចេញពីនាយកដ្ឋានសុខភាពសាធារណៈប្រចាំខោណធីអាឡាមីដាគឺ មានផ្តល់នៅទីនេះ។ ដើម្បីទទួលបាននូវព័ត៌មានថ្មីបំផុតចាប់ថ្ងៃទី 6 មីនាតមកនោះ សូមចុចត្រង់នេះ។
- នៅថ្ងៃទី 7 មីនា នាយកដ្ឋានសុខភាពសាធារណៈប្រចាំខោណធីអាឡាមីដា និងការិយាល័យអប់រំប្រចាំខោណធីអាឡាមីដា បានផ្តល់ការណែនាំ ដោយផ្អែកលើសកម្មភាពមេរោគកូរ៉ូណាដែលមានបួនកំរិត។

នៅគ្រាលំបាកបែបនេះ នៅពេលដែលមានការព្រួយបារម្ភខ្ពស់ យើងខ្ញុំដឹងថាពាក្យចចាមអារាមនានា អាចកើតមានឡើងជាក់ជាមិនខាន។ រាល់ព័ត៌មានទាំងអស់ទាក់ទងនឹងការអាចកើតមានករណីឆ្លងមេរោគកូរ៉ូណាណាមួយ នឹងត្រូវឆ្លងកាត់តាមរយៈការិយាល័យរបស់អគ្គនាយកនៃសង្កាត់សាលារៀនសិន ដោយមានការពិគ្រោះយោបល់ជាមួយនឹងនាយកដ្ឋាន ACOE និង ACPHD។

សំរាប់ព័ត៌មានថែមទៀត សូមចូលគេហទំព័ររបស់យើងនៅ www.ousd.org/coronavirus។ លើសពីនេះទៀត នៅក្នុងកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលនាថ្ងៃពុធនេះ យើងនឹងផ្តល់ព័ត៌មានថ្មីបំផុតជុំវិញមេរោគកូរ៉ូណា និងការឆ្លើយតបរបស់យើងចំពោះមេរោគនេះ។ លោកអ្នកអាចអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំរបស់យើងបានដោយទស្សនាតាមរយៈអិនធឺណិតនៅ www.OUSD.org។

សូមអរគុណចំពោះការគាំទ្រដល់សិស្សានុសិស្ស និងក្រុមគ្រួសាររបស់យើង ព្រមទាំងជួយឱ្យយើងទាំងអស់គ្នា បំពេញកិច្ចការដ៏ពិបាកនេះ ព្រមទាំងស្ថានការណ៍វិវត្តទាំងនេះ៕

ដោយក្តីគោរពស្មោះពី,

ក្រុមទំនាក់ទំនងគ្នាប្រចាំសង្កាត់សាលារៀនអូកឡិនដ៍